ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០២ សហវ.

# សេចក្តីណែនាំ
## ស្តីពី
## វិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

យោងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (មាត្រា១៣៦ និងមាត្រា១៣៧) ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ **ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ**ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ **ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ **អនុក្រឹត្យលេខ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២** ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក **និងប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ លេខ៣២៤** សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** សូមធ្វើការណែនាំអំពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម ៖

## ១. គោលការណ៍ទូទៅ

### ១.១. និយមន័យពាក្យបច្ចេកទេសក្នុងកិច្ចលទ្ធកម្ម

បច្ចេកសព្ទ ឬវាក្យសព្ទទាំងឡាយសម្រាប់គោលបំណងនៃបទប្បញ្ញត្តិនេះ មានអត្ថន័យដូចខាងក្រោម ៖

| | |
|---|---|
| សំណើដេញថ្លៃ | សំដៅដល់សំណុំឯកសារ រួមមាន ឯកសារដេញថ្លៃដែលបានបំពេញដោយអ្នកដេញថ្លៃ និងឯកសារភ្ជាប់មួយចំនួនទៀត ដូចមានតម្រូវក្នុងឯកសារដេញថ្លៃ ដែលអ្នកដេញថ្លៃបានដាក់នៅស្ថាប័នអនុវត្តលទ្ធកម្ម សម្រាប់គោលបំណងផ្គត់ផ្គង់ទំនិញ ទទួលការសំណង់ ផ្តល់សេវាកម្ម ឬសេវាទីប្រឹក្សា។ |
| ប្រាក់កក់ធានាការដេញថ្លៃ | ជាប្រាក់ធានាដែលអ្នកដេញថ្លៃត្រូវកក់មុននឹងចូលរួមការដេញថ្លៃ ដើម្បីធានាថាអ្នកដេញថ្លៃឈ្នះនឹងទទួលយកកិច្ចសន្យា និងចុះកិច្ចសន្យាជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្របតាមពេលវេលាដែលបានកំណត់នៅក្នុងការជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យា។ |
| អ្នកដេញថ្លៃ | សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងចូលរួមក្នុងកិច្ចលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបានដាក់សំណើដេញថ្លៃ ឬសំណើបញ្ជាក់ពីចំណាប់អារម្មណ៍។ |
| ការដេញថ្លៃ | សំដៅដល់ដំណើរការលទ្ធកម្មដែលសំណើដេញថ្លៃត្រូវបានដាក់ ទទួល និងវាយតម្លៃសម្រាប់គោលបំណងប្រគល់កិច្ចសន្យា។ |



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨